**មាត្រា ១៦៖** ជនណាបង្កសម្លេងកងរំពង ឬឈ្លោះប្រកែកគ្នាធ្វើអោយប៉ះពាល់ដល់ភាពស្ងប់ស្ងាត់ និងសណ្តាប់ធ្នាប់សាធារណៈដោយគ្មានការអនុញ្ញាតត្រូវពិន័យជាប្រាក់ ៥.០០០៛ ។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ទ្វេរមួយជាពីរ ។

**មាត្រា១៧ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា១៨ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៤៤ អនក្រ
## ស្តីពីទិដ្ឋាការ-បញ្ជីការឱសថ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

### សំរេច

**មាត្រា ១ :** ឱសថគ្រប់ប្រភេទដែលផលិតក្នុងប្រទេសអាចតាំងលក់បាន លុះត្រាតែមានចុះលេខទិដ្ឋាការយល់ព្រមពីក្រសួងសុខាភិបាល ។

**មាត្រា ២ :** ឱសថគ្រប់ប្រភេទដែលនាំចូលពីបរទេស អាចតាំងលក់បានលុះត្រាតែមានចុះលេខ បញ្ជីការយល់ព្រមពីក្រសួងសុខាភិបាល ។

**មាត្រា ៣** : លក្ខខ័ណ្ឌក្នុងការសុំលេខទិដ្ឋាការៈ បញ្ជីការឱសថ ត្រូវកំណត់ដោយក្រសួងសុខាភិបាល ។

**មាត្រា ៤** : ឱសថដែលបានទទួលលេខទិដ្ឋាការ ឬ បញ្ជីការឱសថពីក្រសួងសុខាភិបាល ត្រូវបង់សោហ៊ុយតាមការកំណត់របស់ក្រសួងសុខាភិបាល ។

**មាត្រា ៥** : ការត្រួតពិនិត្យការផ្តល់ និង ការដកហូតវិញនូវលេខទិដ្ឋាការៈ ឬ បញ្ជីការឱសថជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៦** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាពតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៨** : អនុក្រឹត្យនេះមានអានុភាពជាធរមានអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៤*

# អនុក្រឹត្យលេខ ៤៥ អនក្រ
## ស្តីពីនិយ័តភាពគណនារបស់អាជ្ញាធរ
## អាកាសចរស៊ីវិលកម្ពុជា ពីជំពូក ១១ មកជំពូក ១០

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ១៩៩៣